# រំលឹកជាតខ្មែរ

ដោយមើលឃើញយ៉ាងច្បាស់ថាជាតិមាតុភូមិរបស់យើងកំពុងធ្លាក់ក្នុងគ្រោះមហន្តរាយនឹង រលាយបាត់សូន្យក្នុងកណ្តាប់ដៃនៃពួក រាជានិយម និង ពួកកុម្មុយនិស្តខ្មែរដែលជាខ្ញុំកញ្ជះ ចិន យួន សព្វថ្ងៃនេះ៕

ខ្ញុំខេម រិន្ទ ជាអ្នកតស៊ូម្នាក់ក្នុងរណសិរ្ស(FUNCINPEC)នៅតាមព្រំដែន ខ្មែរ ថៃ ហើយជានិច្ច ជាកាលបានផ្តល់ការគាំទ្រទាំងស្រុងនៅទង្វើ និង សកម្មភាពរបស់លោក សម រង្ស៊ី ប្រឆាំងតទល់ និង រដ្ឋាភិបាល ហ៊ុន សែន ដែលជាអាយ៉ងខ្ញុំកញ្ជះ ចិន យួន កន្លងមក ៕

ប៉ុន្តែថ្ងៃនេះ ខ្ញុំ សូមប្រកាសជំរាបជូនដល់បងប្អូនជនរួមជាតិខ្មែរយើងទាំងអស់ទាំងក្នុង និង ក្រៅប្រទេសអោយបានជ្រាបថាលោក សម រង្ស៊ី និង គណបក្ស សម រង្ស៊ី ក្នុងបច្ចុប្បន្នកាលនេះអស់មាន ជំហរជាអ្នកប្រឆាំងដើម្បីជាតិយើងតទៅទៀតហើយ៕

## *ហេតុអ្វីបានជាខ្ញុំហ៊ាននិយាយរបៀបនេះ ?៖*

ពេលនេះខ្ញុំ ខេម រិន្ទ សូមដាក់ខ្លួនធ្វើជាកញ្ចក់ឆ្លុះមួយផ្ទាំងដើម្បីអោយលោក សម រង្ស៊ី ឆ្លុះមើលនូវ អ្វីដែលគាត់បានធ្វើកន្លងមក អ្វីដែលគាត់កំពុងធ្វើនៅពេលបច្ចុប្បន្ន និង អ្វីដែលគាត់កំពុង នឹងធ្វើនៅពេលអានាគត។

## *ទង្វើ និង សកម្មភាពរបស់លោក សម រង្ស៊ី ពីអតីតកាល ៖*

លោក សម រង្ស៊ី ជាសមាជិកមួយរូបក្នុងរណសិរ្ស *(FUNCINPEC)* គាត់ជាកូនខ្មែរ អ្នកស្នេហាជាតិ ជាអ្នកក្លាហានម្នាក់ដែលគួរអោយកោតសរសើរ និង ជាគំរូដ៏ឆ្នើមសម្រាប់ ជាតិមាតុភូមិ ខ្មែរយើងដែលកំពុងស្ថិតនៅក្នុងកណ្តាប់ដៃនៃពួកកុម្មុយនិស្តមហាផ្តាច់ការដែលបានកាន់កាប់អំណាច តាំងពីឆ្នាំ1979 រហូតដល់សព្វថ្ងៃនេះ។

ប៉ុន្តែ ទង្វើ ភាពក្លាហាន និង រឿងរ៉ាវទាំងអស់ហ្នឹងពុំមែនមានន័យថាលោក សម រង្ស៊ី បានមកពីការខិតខំប្រឹងប្រែងរបស់គាត់ម្នាក់ឯងនោះទេសូមមេត្តាជ្រាបអោយបានច្បាស់រឿងហ្នឹង។

រាល់ទង្វើ និង សកម្មភាពប្រឆាំងដ៏ខ្លាំងក្លាតទល់ជាមួយនឹងពួកអាយ៉ងខ្ញុំកញ្ជះយួន កន្លងមកគឺមានកូនខ្មែរអ្នកស្នេហាជាតិ អ្នកដែលមានឧត្តមគតិជាតិពិតប្រាកដចំនួនរាប់រយនាក់បានផ្តើមគំនិតរួមដៃគ្នាជាមួយលោក សម រង្ស៊ី និង បានធ្វើអោយលោក សម រង្ស៊ីក្លាយទៅជាមនុស្សម្នាក់មានឈ្មោះបោះសំឡេងល្បីល្បាញទូទាំងពិភពលោកថា ជាអ្នកប្រឆាំង ជាមេបក្សប្រឆាំងដ៏ធំនិងមានឥទ្ធិពលបំផុតក្នុងប្រទេសខ្មែរយើងកន្លងមក។

## *ហើយឥឡូវនេះពួកអ្នកស្នេហាជាតិទាំងនោះនៅឯណាខ្លះ ?*

ខ្មែរយើងគ្រប់ៗគ្នាពិតជាបានដឹងបានឮរួចមកហើយថា ក្រោយពីគាត់ សម រង្ស៊ី បំបែក ខ្លួនចេញពីគណបក្ស *(FUNCINPEC)* គាត់បានព្យាយាមបង្កើតគណបក្សថ្មីមួយមានឈ្មោះថា គណបក្ស (ជាតិខ្មែរ) នៅឆ្នាំ1995 ក៏ប៉ុន្តែមិនអាចកើតឡើងបានព្រោះគ្មានការអនុញ្ញាតិពីរដ្ឋាភិបាលរួមបក្សដែលមាន គណបក្ស *( ប្រជាជនកម្ពុជា )( ហ៊្វុនសិនប៉ិច )( សឺន សាន )( មូលីណាកា )* ។

ជាការពិតណាស់ នាពេលនោះគឺមានកូនខ្មែរអ្នកស្រឡាញ់ជាតិមាតុភូមិ មានអ្នកស្អប់ពួកកុម្មុយនិស្ត មានអ្នកស្អប់ពួកក្បត់ជាតិ លក់ជាតិ ។ល។។ល។ មកចូលរួមយ៉ាងសន្ធឹកសន្ធាប ជាហេតុបណ្តាលអោយរដ្ឋាភិបាលរួមបក្ស ដែលដឹកនាំដោយ នរោត្តម រណឫទ្ធិ និង ហ៊ុន សែន មាន ការព្រួយបារម្ភយ៉ាងខ្លាំងថាខ្លួននិងបាត់បង់អំណាចផ្តាច់មុខនៅពេលបោះឆ្នោតឆ្នាំ 1998 ។

ដូច្នេះហើយពួកគេព្យាយាមកំចាត់មនុស្សសំខាន់ៗរបស់គណបក្ស (ជាតិខ្មែរ) នាពេល នោះម្តងមួយៗដោយមិនរើសមធ្យោបាយ មិនរើសវិធី មិនថាទិញជាប្រាក់ ជាការគំរាមកំហែង ជាការ បាញ់សម្លាប់។

## *ហើយជាការពិតមួយដែលលោក សម រង្ស៊ី មិនអាចប្រកែកបាននាពេលនោះគឺះ*

*លោក សម រង្ស៊ី ជាមនុស្សត្រចៀកស្រាលខ្វះការពិចារណាអោយបានល្អិតល្អន់ គាត់ជឿតែពួកដែលអែបអបក្រសោបជើង ទោះបីជាគាត់ដឹងយ៉ាងច្បាស់ថាបុគ្គលនោះជាមនុស្សរបស់ ហ៊ុន សែន ក៏ដោយចុះ។*

ចំណុចខ្សោយរបស់លោក សម រង្ស៊ី ត្រង់នេះគឺជាកំហុសឆ្គងដ៏ធ្ងន់ធ្ងរណាស់ក្នុងឋានះ គាត់ជាអ្នកនយោបាយ ហើយជាចំណុចដែលបង្កអោយមានគ្រោះមហន្តរាយយ៉ាងធុំធេងសម្រាប់អ្នក ស្នេហាជាតិមាតុភូមិ និង អ្នកប្រជាធិបតេយ្យសេរីពិតប្រាកដនោះ។

ក្រោយថ្ងៃរដ្ឋប្រហារ 5-6 កក្កដា 1997 អាយ៉ងកញ្ជះយួន ហ៊ុន សែន បានបំបែក និង កំចាត់មនុស្សសំខាន់ៗដែលស្មោះចំពោះតែលោក រង្ស៊ី ស្ទើរតែអស់រលីង រួចហើយគេចាប់ផ្តើម បញ្ចូលមនុស្សរបស់គេ ទៅក្នុងគណបក្ស សម រង្ស៊ី ដែលបានផ្តូរឈ្មោះពីគណបក្ស *(ជាតិខ្មែរ)* ជាបន្តបន្ទាប់ដោយមានមនុស្សរបស់គេស្រាប់ជាអ្នកចាត់ចែងផ្ទៃក្នុងរហូតដល់បច្ចុប្បន្ននេះ ។

ចាប់តាំងពីថ្ងៃបោះឆ្នោតឆ្នាំ1998 ដល់ថ្ងៃបោះឆ្នោតឆ្នាំ2008 គឺមានរយះពេល 10 ឆ្នាំ ខ្ញុំមើលឃើញយ៉ាងច្បាស់ថាគណបក្ស សម រង្ស៊ី ដែលធ្លាប់តែមានភាពក្លាហានមុះមុតក្នុងការប្រឆាំងហ៊ានរិះគន់ខ្លាំងៗទៅលើរដ្ឋាភិបាលអាយ៉ង កញ្ជះចិន កញ្ជះយួន ហ៊ុនសែន ដោយមិនញញើតមិន ក្រែងរអែងនូវការ គំរាម កំហែងទាំងឡាយទាំងពួង ប៉ុន្តែ ពួកគេបានប្រែក្លាយ ទៅជាគណបក្ស ផ្សំរួមសី ពួកគេបន្ទន់ឥរិយាបថដែលគួរ អោយស្អប់ខ្ពើម ខ្ញុំជឿថាជនរួមជាតិខ្មែរយើងទាំងអស់ពិតជាបានជ្រាប រួចមកហើយនូវការផ្លាស់ប្តូរដែលមិនប្រក្រតីនេះ ៕

## *តើការផ្លាស់ប្តូរឥរិយាបថរបស់គណបក្ស សម រង្ស៊ី ពីការប្រឆាំងមកមិនប្រឆាំងវិញហ្នឹងគឺមានមូលហេតុអ្វីខ្លះ ?*

## *គឺមានមូលហេតុ04 ប្រការ ៖*

1-លោក សម រង្ស៊ី អសមត្ថភាពក្នុងការគ្រប់គ្រងបក្ស ។
2-មនុស្សសំខាន់ក្នុងបក្សបានក្លាយទៅជាមនុស្សរបស់ ហ៊ុន សែន.ជា សីម.ហេង សំរិន ។
3-គណបក្សប្រជាជនកម្ពុជាមិនអនុញ្ញាតិអោយលោក សម រង្ស៊ី ធ្វើសកម្មភាពក្នុងស្រុកខ្មែរ។
4-ជាហេតុផលសំខាន់បំផុតដែលបងប្អូនជនរួមជាតិខ្មែរទាំងអស់ត្រូវតែដឹងអោយបានច្បាស់ថាមាននរណាខ្លះឈរនៅពីក្រោយខ្នងលោក សម រង្ស៊ី តាំងពីអតីតរហូតដល់បច្ចុប្បន្ន ?

## *ខ្ញុំសូមអធិប្បាយដូចតទៅនេះ៖*

1- ក្រុមប្រទេសលោកសេរី មាន អាមេរិកាំង.អង្គ្លេស.បារាំង។ល។។ល។

*2- ក្រុមពួកកម្មុយនិស្ត មាន សីហនុ ក្រោយសីហនុ មានចិន មានម៉ូនិក ក្រោយម៉ូនិក មានហ៊ុន សែន ក្រោយហ៊ុន សែន មានយួន ។*

ក្រុមកម្មុយនិស្តនេះហើយដែលធ្វើអោយលោក សម រង្ស៊ី វិលក្បុងផុងដកខ្លួនមិនរួច រហូតដល់ធ្វើអោយក្រុមលោក សេរី គេព្រងើយកន្តើយគេមិនរវីរវល់ជាមួយនិងគាត់ទៀតទេដូចដែលយើង ឃើញស្រាប់ហើយ ។

## ព្រោះហេតុអ្វី ?

ព្រោះថានៅពេលដែលក្រុមលោកសេរី គេចង់បានគេប្រាថ្នានឹងអោយលោក សម រង្ស៊ីធ្វើអ្វី មួយដើម្បីជាតិមាតុភូមិរបស់យើង លោក សម រង្ស៊ីខ្លួនឯងតែងតែយកសេចក្តីប្រាថ្នារបស់គេទៅប្រឹក្សា និងសុំយោបល់ សុំការអនុញ្ញាតិ ពីសីហានុជាមុនសិន សួរថាតើសីហានុយល់ព្រមដែរឬ? ចម្លើយគឺអត់ទេ

ទង្វើទាំងអស់ហ្នឹងរបស់លោក រង្ស៊ី ជាហេតុបណ្តាលអោយខ្លួនគាត់រសាត់អណ្តែតនៅក្រៅស្រុករហូតដល់សព្វថ្ងៃនេះ។

ហេតុផលធំៗទាំង 4 ប្រការខាងលើនេះគឺបង្កបង្កើតឡើងដោយគណបក្សប្រជាជនកម្ពុជា។

## *ទង្វើ និង សកម្មភាពរបស់លោក សម រង្ស៊ី បច្ចុប្បន្ន ៖*

ក្រោយថ្ងៃបោះឆ្នោតឆ្នាំ2008 រហូតដល់សព្វថ្ងៃនេះគណបក្ស សម រង្ស៊ី គឺនៅសល់តែឈ្មោះតែប៉ុណ្ណោះ ព្រោះថាពួកអាយ៉ងកញ្ជះយួន ហ៊ុន សែន *បានស្រូបយកព្រលឹងអ្នកស្រឡាញ់ជាតិ ស្រឡាញ់លទ្ធិប្រជាធិបតេយ្យ ទៅដាក់ក្នុងក្អមបណ្តែតទឹកនៅទន្លេចតុមុខបាត់ទៅហើយ គឺនៅសល់តែមនុស្សរបស់ សម រង្ស៊ី តែព្រលឹងរបស់ ហ៊ុន សែន ចូលមកស្ថិតនៅជំនួសវិញ ។*

បច្ចុប្បន្ននេះរដ្ឋាភិបាលអាយ៉ងកញ្ជះ ចិនយួនដែលមាន ហ៊ុន សែន ជាប្រមុខនោះបានចាត់ទុកគណបក្ស សម រង្ស៊ី ត្រឹមតែគណបក្ស *ចំណុះអោយរដ្ឋសភាតែប៉ុណ្ណោះគឺ មានក៏បានមិនមានក៏បាន* ប៉ុន្តែហេតុអ្វីគេត្រូវតែអោយមាន ? គឺអោយមានដើម្បីបំពេញកៅអីក្នុងរដ្ឋសភាដែលពួកគេបន្សល់ទុក អោយ *សម្រាប់លំអអោយរដ្ឋាភិបាលអាយ៉ងចិនយួនតែប៉ុណ្ណោះ ។*

## *តើពួកអាយ៉ងកញ្ជះចិន យួន ធ្វើរបៀបនេះគឺគេធ្វើដើម្បីអ្វី ?*

1- ដើម្បីតម្រូវចិត្តពួកក្រុមលោកសេរី ដែលជាម្ចាស់ជំនួយដ៏ធំសម្រាប់កម្ពុជាបច្ចុប្បន្ន ។

2- ដើម្បីលំអររដ្ឋសភាខ្មែរដែលជាអាយ៉ងកញ្ជះចិន យួន ។

3- ដើម្បីលំអររដ្ឋាភិបាលមហាផ្តាច់ការអាយ៉ងកញ្ជះចិន យួន ។

4- ដើម្បីបោកប្រាស់សតិអារម្មណ៍ជាតិ និង អន្តរជាតិអោយយល់ច្រឡំថាប្រទេសខ្មែរកំពុងមានលទ្ធិប្រជាធិបតេយ្យពេញបរិបូរណ៍ ។

5- ដើម្បីការពារមិនអោយគណបក្ស សម រង្ស៊ី ដកខ្លួនចេញពីការបោះឆ្នោតឬហៅថាពហិការនៃការបោះឆ្នោតនៅឆ្នាំ2013 ខាងមុខនេះ ។

6 - ដើម្បីការពាររក្សាអំណាចផ្តាច់ការនិងផ្តាច់មុខជានិរន្តន៍ ។

## *ទង្វើ និង សកម្មភាពរបស់លោក សម រង្ស៊ី នៅអនាគត់ ៖*

*សព្វថ្ងៃនេះទាំង នយោបាយ ទាំងសេដ្ឋកិច្ច ទាំងសង្គម ទាំងកងកម្លាំងប្រដាប់អាវុធ របស់ ជាតិខ្មែរត្រូវបានគ្រប់គ្រងទាំងស្រុងដោយ ចិន និង យួន ចំណែករដ្ឋាភិបាលអាយ៉ង ហ៊ុន សែន ដែលកំពុងគ្រប់គ្រងអំណាចផ្តាច់មុខហ្នឹង គឺគ្រាន់តែជាកូនអុកនៅក្នុងដៃរបស់គេតែប៉ុណ្ណោះ ។*

*គណបក្ស ប្រជាជនកម្ពុជាមិនចង់អោយមានរូបលោក សម រង្ស៊ី រស់នៅលើលោកយើងនេះទៀតទេ ប៉ុន្តែចាំបាច់គេត្រូវតែអនុគ្រោះមួយរយះសិន ព្រោះអីគេមានផែនការថ្មីស្រឡាងមួយដែលអាចកំចាត់លោក សម រង្ស៊ី បានដោយមិនចាំបាច់សម្លាប់ឬចាំដាក់គុកទៀតទេ ។*

*តើគណបក្ស ប្រជាជនកម្ពុជាគេមានផែនការណ៍អ្វីខ្លះ ?*

## *ផែនការណ៍នោះគឺមាន 5 ៖*

*1- អោយ គឹម សុខា ប្រធានគណបក្ស សិទ្ធិមនុស្ស ដែលជាកូនសំពាយរបស់ខ្លួនស្រាប់បញ្ចុះបញ្ចូល សម រង្ស៊ី អោយបង្កើតគណបក្សថ្មីមួយដើម្បីទាញយក សម រង្ស៊ី ចេញអោយផុតពីគណបក្ស សម រង្ស៊ី ។*

*2- គណបក្សថ្មីមួយដែលមានតែឈ្មោះថា បក្ស(សង្គ្រោះជាតិ) តែសង្គ្រោះខ្លួនឯងមិនរួច ។*

*3- ធ្វើអោយ សម រង្ស៊ី ប្រកាសដើរចេញពីគណបក្ស សម រង្ស៊ី ឬបក្ស ផ្សំ រួម សី ដោយខ្លួនឯង ។*

*4- រក្សានិងការពារអោយបាននូវ គណបក្ស សម រង្ស៊ី និង គណបក្ស សិទ្ធិមនុស្ស អោយនៅគង់វង្សដដែល ដើម្បីជាខែល នៃលទ្ធិប្រជាធិបតេយ្យក្លែងក្លាយរបស់ពួកគេទៅថ្ងៃមុខ ព្រោះថាទោះជាយ៉ាងណាក៏គណបក្សដែលមិនប្រឆាំងទាំងពីរនេះបានក្លាយទៅជាកូនសំពាយរបស់ពួកគេជាយូរយាណាស់មកហើយដែរ*

*5- បំភ័ន្ត ភ្នែកជាតិ និង អន្តរជាតិអោយយល់ច្រឡំថា សម រង្ស៊ី កំពុងដើរឆ្ពោះទៅរកជ័យជំនះក្នុងនាមជាប្រធាន គណបក្សសង្គ្រោះជាតិ ។*

ផែនការណ៍ដ៏ល្អរបស់គណបក្ស កម្មុយនិស្តដែលជាខ្ញុំកញ្ជះ ចិន យួន លើកនេះ ខ្ញុំ ខេម រិទ្ធ មើលឃើញយ៉ាងច្បាស់ថាលោក សម រង្ស៊ី កំពុងដើរទៅតាមអ្វីដែលជាគំនូសដែលពួកយួន គេបាន គូសអោយដើរ

លោក សម រង្ស៊ី នៅពេលនេះ ប្រៀបដូចជាមនុស្សកំពុងតែពុល *ទឹកតែអុង* គាត់កំពុងលង់ផុង ខ្លួនយ៉ាងជ្រៅទៅក្នុងក្ដីស្រមើលស្រមៃថាខ្លួនជា អ្នកខ្លាំង ជាអ្នកឈ្នះ ក្នុងល្បែងនយោបាយផ្សងព្រេង ដែលមានយួន ជាអ្នកកំណត់សន្លឹកឆ្នោតរបស់ជាតិខ្មែរ ។

គណបក្ស ប្រជាជនកម្ពុជា មានការលំបាកយ៉ាងខ្លាំងចំពោះរូបលោក សម រង្ស៊ី កន្លងមក ព្រោះថាទាល់តែមានរូបលោក សម រង្ស៊ី ចូលរួមក្នុងការបោះឆ្នោតទើបត្រឹមត្រូវនិងយកជាការបាន ទោះបីជាពួកគេដឹងហើយថា ការបោះឆ្នោតក្នុងប្រទេសខ្មែរយើងបច្ចុប្បន្ន *កុំថាឡើយតែលោក សម រង្ស៊ី* ***សូម្បី តែខ្មោច នរោត្តម សីហានុ ដើបឡើងពីម្ឈូសមកឈរឈ្មោះអោយជនជាតិខ្មែរ បោះឆ្នោតអោយកមិនអាចឈ្នះពួកគេបានដែរ ។***

*សូមបងប្អូនជនរួមជាតិខ្មែរទាំងអស់ក្រឡេកទៅមើលដំណើរវិវឌ្ឍន៍នៃគណបក្សដែលខ្មែរយើងនាំគ្នាហៅជាប់មាត់ថា បក្សប្រឆាំង ១១១ ក្នុងពេលបច្ចុប្បន្ន ។*

ឥឡូវនេះយើងឃើញលោក សម រង្ស៊ី កំពុងស្រែកប្រកូកប្រកាសដូចមនុស្សពុល **ទឹកតែអុង** អញ្ចឹង គាត់ស្រែកថាគាត់កំពុងតែរួបរួមគណបក្សប្រឆាំង រួបរួមអ្នកស្រឡាញ់ជាតិស្រឡាញ់មាតុភូមិស្រឡាញ់លទ្ធិប្រជាធិបតេយ្យសេរីពិត ។

*ប៉ុន្តែអ្វីៗ ដែលគាត់ រង្ស៊ី កំពុងតែធ្វើនោះគឺ វាផ្ទុយស្រឡះពីការនិយាយរបស់គាត់ ព្រោះថា ពីមុនមានគណបក្សប្រឆាំងតែ 2 ទេប៉ុន្តែក្រោយពីការរួបរួមរបស់គាត់ វាគួរតែមានគណបក្សប្រឆាំងតែ*

## *(1) ហេតុអ្វីមានដល់ទៅ 3* បក្ស

## *សួរថាតើការរួមគ្នារបស់គាត់ហ្នឹងមានន័យដូចម្ដេច ?*

1- គណបក្ស សម រង្ស៊ី ឬ បក្ស (ផ្សំ រួម សី) ។

2- គណបក្ស សិទ្ធិមនុស្ស ។

3- គណបក្ស សង្គ្រោះជាតិ ។

បើយើងរាប់លេខគឺ *1-2-3* ប៉ុន្តែខ្ញុំឮតែបងប្អូនខ្មែរយើងទាំងនៅក្នុងប្រទេសនិងក្រៅប្រទេស

មានសេចក្តីរីករាយសប្បាយណាស់ ហើយមានសង្ឃឹមយ៉ាងមុតមាំថា គណបក្សប្រឆាំងដែលដឹកនាំ ដោយ លោក សម រង្ស៊ី ពិតជា ឈ្នះ ឈ្នះ ហើយ ឈ្នះ នៅពេលបោះឆ្នោតនាឆ្នាំ 2013 ខាងមុខនេះ ។

## ប៉ុន្តែចំពោះខ្ញុំវិញ ខេម រិទ្ធ មើលឃើញតែ ៖

*1- លោក សម រង្ស៊ី កំពុងតែបោកក្រាសសេចក្តីទុកចិត្តរបស់ជាតិខ្មែរយើងទាំងក្តីងដើល ព្រោះថា គាត់កំពុងតែ បំបែកបក្ស មិនមែន រួមបក្សទេ ។*

*2- លោក សម រង្ស៊ី កំពុងចាញ់បោកគណបក្ស ប្រជាជនកម្ពុជា ម្តងនេះមិនមែនចាញ់ធម្មតាទេ គឺ ចាញ់ផ្កាប់មុខតែម្តង ។*

## ហេតុអ្វីបានជាខ្ញុំហ៊ាននិយាយដូច្នេះ ?

*ព្រោះថាការរួមគ្នាគឺ ទាល់តែ គណបក្ស សម រង្ស៊ី និង គណបក្ស សិទ្ធិមនុស្ស រួមបញ្ចូលគ្នាតែមួយ ដែលមានឈ្មោះថា គណបក្សសង្គ្រោះជាតិ ហ្នឹង គឺមិនត្រូវមាន គណបក្ស សម រង្ស៊ី និង គណបក្ស សិទ្ធិមនុស្ស ចូលរួមក្នុងការបោះឆ្នោតជាតិនៅឆ្នាំ 2013 នោះទៀតទេ បើធ្វើបែបនេះទើប ហៅថាជាការរួមបក្ស រួមសន្លឹកឆ្នោតតែមួយ ។*

*បើមិនដូច្នោះទេ គណបក្សថ្មីមួយ ដែលមានឈ្មោះថា សង្គ្រោះជាតិ ហ្នឹង គឺប្រៀបដូចជា គណបក្ស ស្រមោលគ្មានរូបរាង្គ កុំថាឡើយទៅសង្គ្រោះជាតិ សង្គ្រោះតែរូបលោក សម រង្ស៊ី ខ្លួនឯង មិនបានផង ។*

*ខ្ញុំជឿជាក់ថានេះជាការបណ្តេញលោក សម រង្ស៊ី ចេញពីគណបក្សរបស់ខ្លួនដោយយុទ្ធវិធី ត្រជាក់ជាទីបំផុត ដែលលោក រង្ស៊ី ខ្លួនឯងមិនអាចប្រកែកបានឡើយ ។*

*សួរថានៅពេលដែល សម រង្ស៊ី បានប្រកាសលាចេញពីតំណែងប្រធានគណបក្សសម រង្ស៊ី ហើយនោះតើគាត់អាចត្រឡប់ចូលមកកាន់តំណែងជាប្រធានបក្សដូចដើមវិញបានឬអត់ ?*

## ចម្លើយគឺអត់បានជាដាច់ ៖ ព្រោះហេតុអ្វី ?

*ព្រោះថាពួកគេរងចាំឱកាសដ៏សែន ល្អកម្ររកបានបែបនេះ មកជាយូរឆ្នាំមកហើយ វាជាឱកាសដែលពួកអាយ៉ងខ្ញុំកញ្ជះបរទេស ចិន យួន អាចបង្ក្រាបលោក សម រង្ស៊ី អោយជាតិ និង អន្តរជាតិ ឃើញថា អត់ពីលោក សម រង្ស៊ី ក៏គណបក្ស សម រង្ស៊ី រស់បានដែរ នឹងពូកែប្រឆាំងជាង មុនទៅទៀត ហើយខ្ញុំជឿទៀតថា សម រង្ស៊ី នឹង ត្រូវបាត់បង់តំណែងជាប្រធានបក្សប្រឆាំងដ៏ធំ ក្នុងប្រទេសកម្ពុជាយើងនេះជារៀងរហូត ទោះបីជាគាត់បានរៀបចំទុកនូវអ្វីៗដូចដែលកើតមានក្នុង សមាជ គណបក្ស សម រង្ស៊ី កាលពីថ្ងៃទី 2 ខែវិច្ឆិកា កន្លងមកនេះ ក៏ដោយចុះក៏គាត់មិនអាចទប់ស្កាត់បាននៅ ល្បិច កល ដ៏សែនត្រជាក់របស់គណបក្សប្រជាជនកម្ពុជាលើកនេះបានដែរ ព្រោះគេមានយុទ្ធវិធីល្អៗជាច្រើនទៀត សម្រាប់កំចាត់លោក សម រង្ស៊ី ចេញអោយដាច់ស្រឡះពី គណបក្ស សម រង្ស៊ី ដោយមានមនុស្សរបស់លោក សម រង្ស៊ី ដែលគេទិញក្បាលបានហ្នឹងជាជំហរប្រឆាំងនិងលោក សម រង្ស៊ី ដោយផ្ទាល់តែម្តង ។*

*ហើយរឿងមួយទៀតដែលគួរអោយអស់សំណើចនោះគឺ នៅពេលដែលលោក សម រង្ស៊ី ដឹងថា ខ្លួនអស់សិទ្ធិលើគណក្សសមរង្ស៊ីហើយនោះក្តីក៏គាត់ហ្នឹងត្រូវតែរត់ត្របាញ់ជើងទៅ លួងលោមគេខ្លះបោកប្រាសគេខ្លះនៅឯក្រៅប្រទេសដើម្បីរកប្រាក់មកចិញ្ចឹមគណបក្ស សម រង្ស៊ី ដែលមានប្រព័ន្ធនិង កូនចៅ តូចៗ របស់ខ្លួនដែលកំពុងជាប់ផុងលង់ខ្លួនក្នុងគណបក្ស សម រង្ស៊ី ហ្នឹង ។*

## *ខាងក្រោមនេះខ្ញុំសុំធ្វើការវិភាគត្រួសៗ វិភាគបែបភ្លើៗ ៖*

*ខ្ញុំមើលឃើញថាការបោះឆ្នោតឆ្នាំ 2013 នេះគណបក្ស សង្គ្រោះជាតិ និង បានទទួលសម្លេងឆ្នោត មិនលើសពីការកំណត់របស់គណបក្ស ប្រជាជន ឡើយ គឺប្រាំ(5) កៅអី យ៉ាងច្រើន ។*

*ប៉ុន្តែពួកគេ និង តំឡើងកៅអីអោយគណបក្ស សម រង្ស៊ី និង គណកបក្ស សទ្ធិមនុស្ស ដែលក្លាយទៅជាកូនសំពាយរបស់គេច្រើនជាងមុន ដើម្បីលើកទឹកចិត្ត ហើយជាការពិតណាស់ ពួកគេ និង អនុញ្ញាតិអោយគណបក្សទាំង 2 ហ្នឹងសម្តែងការប្រឆាំងខ្លាំងក្លាជាងមុនទៅទៀតដើម្បីសម្តែង អោយជាតិ និង អន្តរជាតិឃើញថា អត់ពីលោក សម រង្ស៊ី ក៏មានអ្នកប្រឆាំងដែរ ប៉ុន្តែប្រឆាំងតាមអ្វី ដែលគេបានកំណត់អោយ ហ្នឹង ។*

### ***រដ្ឋធម្មនុញ្ញខ្មែរយើងចែងថា គណបក្ស(មួយណា) ទទួលបានសន្លឹកឆ្នោតលើសពី 50 កៅអី គឺឈ្នះ ហើយមានសិទ្ធិរៀបចំរដ្ឋាភិបាល ៖***

*1- សួរថាតើគណបក្ស សង្គ្រោះជាតិ អាចនិងទទួលបានសន្លឹកឆ្នោតលើសពី 50 កៅអីឬ? ខ្ញុំមើលឃើញតែ 05 កៅអី យ៉ាងច្រើន ។*

*2- គណបក្ស សម រង្ស៊ី អាចទទួលបានដល់ទៅ 30 កៅអី ។*

*3- គណបក្ស សិទ្ធិមនុស្ស អាចទទួលបានដល់ទៅ 6 កៅអី ។*

*បើយើងគិតលេងៗទៅតាមនេះ ឃើញថា 03 គណបក្សបានទទួលសន្លឹកឆ្នោត 41 កៅអី ក្នុងរដ្ឋសភាខ្មែរ ហើយខ្ញុំជឿជាក់ថា គណបក្សប្រជាជន គេហ៊ានអោយ 41 កៅអីនេះ ដើម្បីទិញទឹកចិត្តគណបក្សដែលលែងប្រឆាំងដើម្បីប្រយោជន៍ជាតិ ទាំង 03 នោះ ។*

*ប៉ុន្តែគណបក្ស ប្រជាជនកម្ពុជា គេយកតែ 70 កៅអី គេអោយទៅគណបក្ស ហ៊្វុនស៊ីនប៉ិក 04 កៅអី ឬ គណបក្សជាតិនិយម 04 និង គណបក្សផ្សេងៗទៀត 04 កៅអី ។ល។ ។ល។ រួមគ្នាទៅបាន 82 កៅអី*

សួរថាតើគណបក្សណាជាអ្នករៀបចំរដ្ឋាភិបាល នៅឆ្នាំ2013 នោះ ហើយជាការពិតណាស់ នៅមុនពេលបោះឆ្នោតឆ្នាំ 2018 ពួកគេ និង តំឡើង អាសនៈនៅក្នុងរដ្ឋសភាអាចពី 123 ទៅ 130 ឬ 135 ដើម្បីចែកចាយបន្ថែម ដោយសំអាងទៅលើកំណើនប្រជាពលរដ្ឋ ។ល។ ។ល។

. *តទៅនេះខ្ញុំសូមធ្វើការអំពាវនាវដល់បងប្អូនជនរួមជាតិខ្មែរយើងទាំងអស់គ្នាមេត្តាភ្ញាក់រលឹក ឡើងក្រោកឈរឡើងព្រមៗគ្នារួមសាមគ្គីគ្នាដើម្បី រក្សាការពារ ជាតិមាតុភូមិ ជាកេរ្តិ៍មរតករបស់ មហាបុព្វបុរសខ្មែរយើងដែលកំពុងត្រូវបានពួក វាជានិយម នឹង ពួកកម្មុយនិស្ត ខ្ញុំ ញុំកញ្ច្រះ ចិន កញ្ច្រះយួន បំផ្លិចបំផ្លាញអស់ស្ទើគ្មានសល់ ។*

## *ជាការពិតណាស់ដែលថាគណបក្ស ប្រជាជនកម្ពុជា នេះជាគណបក្សរបស់យួន ៖*

គណបក្ស ប្រជាជនកម្ពុជា *បង្កើតឡើងដោយ ហូជីមិញ នៅថ្ងៃទី 28 ខែ មិថុនា ឆ្នាំ 1951 ដោយបានតែងតាំងអោយលោក សឺង ង៉ុក មិញ ជាអ្នកដឹកនាំនាពេលនោះ ។*

ដូច្នេះពុំមែនជាការចំឡែកអ្វីទេ ចំពោះគណបក្សកម្មុយនិស្តខ្មែរមួយនេះ ខ្ញុំជឿជាក់ថាខ្មែរយើងគ្រប់ៗគ្នាពិតជាបានដឹងបានឮ និង បានរស់នៅក្រោមរបបប្រល័យពូជសាសន៍ខ្មែរក្រហម ចាប់តាំង *ពីថ្ងៃទី 17 មេសា ឆ្នាំ 1975 រហូតមកដល់បច្ចុប្បន្នកាលនេះ ប្រទេសកម្ពុជាយើងត្រូវបានគ្រប់គ្រង និង បំផ្លិចបំផ្លាញដោយគណបក្សតែមួយនេះ ។*

ឥឡូវនេះបញ្ហាដែលយើងជាជាតិខ្មែរគ្រប់ៗគ្នាត្រូវតែគិតត្រូវតែបារម្មណ៍ និង ត្រូវតែរួមគ្នាធ្វើ

ដោយខានមិនបានោះគឺ បញ្ឈប់ជាបន្ទាន់នូវ អន្តោប្រវេសន៍យួនខុសច្បាប់រាប់លាននាក់ដែលកំពុង រស់នៅ និង កំពុងហូរចូលបន្ថែមយ៉ាងគគ្រឹកគគ្រេងរៀងរាល់ថ្ងៃនេះ ។

ហេតុអ្វីបានជារដ្ឋាភិបាលកម្មុយនិស្តយួន ក្រុងហាណូយគេខិតខំប្រឹងប្រែង បញ្ចូល និង បញ្ជូនជនជាតិគេច្រើនសន្ធឹកសន្ធាប់អោយចូលមករស់ក្នុងប្រទេសរបស់យើង ?

## មានហេតុផលធំតែមួយគត់គឺ ៖

*ដើម្បីបង្គ្រប់សន្លឹកឆ្នោត 2/3 នៃអាសនៈនៅក្នុងរដ្ឋសភាខ្មែរយើងនាអំឡុងការបោះឆ្នោតឆ្នាំ 2023 ឬ 2028 ខាងមុខនេះ ដូច្នេះខ្ញុំសូមបញ្ជាក់ម្តងហើយម្តងទៀតដល់អ្នកនយោបាយទាំងឡាយដែលកំពុងសប្បាយភ្លើតភ្លើន និង កៅអី ដែលយួនគេតំឡើងអោយក្នុងមួយអណត្តិ 2 ឬ 3 កៅអីហ្នឹង ថាខ្លួនគ្រាន់បើនោះ អត់ផ្លូវទេ ចោលម្សៀតទាំងអស់ ។*

*យួនគេមិនត្រូវការសន្លឹកឆ្នោតត្រឹមតែ 50+1 នោះទេ ប៉ុន្តែគេត្រូវការដល់ទៅ 2/3 ឯណ្ណោះ ទើបវាគ្រប់អាសនៈ ដើម្បីលេបត្របាក់យកជាតិមាតុភូមិជាទីស្រឡាញ់នៃខ្មែរយើង ដោយមិនចាំបាច់លើកកម្លាំងទ័ពមកបុករុកឈ្លានពានប្រទេសខ្មែរយើងដូចពេលមុនៗនោះទៀតទេ គឺគេលេបត្របាក់យក តាមរយៈការបោះឆ្នោតនៃ របបប្រជាធិបតេយ្យ ដែលអាស្រ័យយួនជាអ្នកកំណត់សន្លឹកនេះឯង ។*

*បច្ចុប្បន្ននេះពួកចោរយួនចង្រៃមិនចេញមុខដឹកនាំរដ្ឋទេ ព្រោះមិនទាន់មានកម្លាំងគ្រប់គ្រាន់ គេនៅបារម្មណ៍ថា គណបក្សប្រជាជនកម្ពុជា មិនព្រម ប៉ុន្តែពួកគេបានសម្តែងអោយខ្មែរយើងដែលជាម្ចាស់ប្រទេសឃើញជាញ៉យញ៉យមកហើយថា ពិតជាពុំមានឧបសគ្គអ្វីបន្តិចសោះឡើយសម្រាប់ពួកគេក្នុងគោលដៅដើម្បីកាន់កាប់អំណាចរដ្ឋរបស់ខ្មែរយើងទាំងស្រុងនោះ ។*

## *សូមផ្តាំទុកជាមុនៈ*

យួនគេត្រូវការសន្លឹកឆ្នោត *2/3* នៃកៅអី ក្នុងរដ្ឋសភាខ្មែរយើង គេមិនមែនត្រូវការត្រឹមតែ *50+1* នោះទេ ។

***ស៊ូស្លាប់ខ្លួន មិនអោយស្លាប់ជាតិ មិនចោលម្សៀតដូចជាយួនគិត***

***កូនខ្មែរ ពូកែពិត អាយួនអស់រិទ្ធិ គិតមិនដល់***

*ធ្វើនៅថ្ងៃទី 09 ខែ វិច្ឆិកា ឆ្នាំ 2012*

*ខេម រិទ្ធ*